00475758

ឯកសារដើម / ORIGINAL/ORIGINAL: D 345/3

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១០

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 15 / 02 / 2010
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបសំណើសុំរបស់លោក អៀង សារី**

**ស្ដីពីការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | |
|---|---|---|
| **សហមេធាវី៖** | **សហចៅក្រមស៊ើបអង្កេត៖** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម Marcel LEMONDE | លោក Andrew CAYLEY |
| | | **ក្រុមមេធាវីការពារក្ដីទាំងអស់** |

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("សហមេធាវីការពារក្តី") អនុលោមតាម វិធានផ្ទៃក្នុង ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន") សូមដាក់សំណើស្តីពីព្រំដែនកម្រិតនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅ បើសិនជាការទទួលខុសត្រូវនេះត្រូវយកមកអនុវត្តនៅ អ.វ.ត.ក ។ មេធាវីការពារក្តីសូមស្នើថា ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺមិនអាចយកមកអនុវត្តនៅ អវតក ឡើយ[1]។ ប៉ុន្តែប្រសិនបើ អ.វ.ត.ក សម្រេចថា ខ្លួនមានយុត្តាធិការក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើមែននោះ ទោះបីជាមានទឡ្ហីករណ៍ទាំងអស់ផ្ទុយពីនេះក៏ដោយ ក៏ ១) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ២) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកអនុវត្តបានតែចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ ៣) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានចំពោះតែមេដឹកនាំយោធាប៉ុណ្ណោះ ៤) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកអនុវត្តបានតែនៅពេលណាដែលមានទំនាក់ទំនងហេតុនិងផលរវាងអំពើរបស់មេដឹកនាំ និងបទល្មើសរបស់អ្នកនៅក្រោមបង្គាប់មេដឹកនាំនោះ និងនៅពេលដែលមានបទល្មើសទាក់ទងនឹងសកម្មភាពទាំងឡាយដែលថ្នាក់លើមានកាតព្វកិច្ចផ្លូវច្បាប់ដែលកើតមានជាមុនរួចជាស្រេចដើម្បីបង្ការនិងដាក់ទោស និង ៥) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តចំពោះបទល្មើសដែលមានចេតនាពិសេស ដូចជាអំពើប្រល័យពូជសាសន៍ជាដើមឡើយ។ មានឧបសម្ព័ន្ធមួយត្រូវបានភ្ជាប់មកជាមួយ ដែលបានចែងពីអង្គច្បាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយសារតែវាបានវិវត្តតាមរយៈយុត្តិសាស្ត្ររបស់សាលាក្តី*ចំពោះកិច្ច ad hoc* និងដោយសារតែវាត្រូវបានគេតាក់តែងជាច្បាប់នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។

## I. ការទទួលយកបាននៃសំណើនេះ

១. វិធាន ៥៥(១០) អនុញ្ញាតិឲ្យភាគីស្នើសុំឲ្យ កសចស ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ឬចាំបាច់ដល់ការស៊ើបសួរ[2]។ ក.ស.ច.ស បានបញ្ជាក់ពី

---

[1] *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំរបស់លោកអៀង សារី ប្រឆាំងនឹងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០។

[2] ក.ស.ច.ស បានកត់សម្គាល់ថា មិនដូចវិធានផ្ទៃក្នុងផ្នែកជាភាសាអង់គ្លេស ដែលតម្រូវថាដីកាដែលត្រូវបានស្នើ ឬកិច្ចស៊ើបសួរត្រូវតែ "ចាំបាច់" ផ្នែកជាភាសាបារាំងគ្រាន់តែចែងថាវាត្រូវតែ "មានប្រយោជន៍"។ *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D97/13, ERN: 00411047-

មុនថា សំណើសុំរបស់ អៀង សារីប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.កជាទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម (សំណើសុំ JCE)[3] គួរត្រូវបានពិចារណាឱ្យបានសមស្របនៅក្រោមវិធាន ៥៥(១០)[4]។ សំណើសុំបច្ចុប្បន្នស្រដៀងនឹងសំណើសុំ JCE ៖ សំណើសុំនេះស្នើថា ទម្រង់នៃការទទួលខុសត្រូវដែលមិនមានចែងនៅក្នុងច្បាប់កម្ពុជា និងមិនមាននៅក្នុងទម្លាប់អន្តរជាតិនៅពេលវេលាដ៏សមស្របមួយ អាយយកមកអនុវត្តនៅ អ.វ.ត.ក តែក្នុងរបៀបមួយដែលមានព្រំដែនកម្រិត បើសិនជាការទទួលខុសត្រូវនេះត្រូវបានកំណត់ថាអាចយកមកអនុវត្តបានទោះតាមវិធីណាក៏ដោយ។ ផ្ទុយពីសហឧក្រិដ្ឋកម្មរួមដែលមិនមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់បង្កើត អ.វ.ត.ក ការទទួលខុសត្រូវរបស់ថ្នាក់លើ មានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក។ ទោះយ៉ាងនេះក៏ដោយ សំណើសុំបច្ចុប្បន្ននេះមិនបានស្នើសុំស្រាយច្បាប់នោះទេ[5]។

២. ក្នុងការពិភាក្សាអំពីការអនុវត្តបទល្មើសប្រល័យពូជសាសន៍នៅ អ.វ.ត.ក ក.ស.ច.ស បានបញ្ជាក់

---

00411056, ជើងទំព័រ២៣ ("ដីកា JCE")។ សូមមើលរឿងក្តី អៀង សារី, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D97/13, ERN: 00411047-00411056, ជើងទំព័រ២៣ ("ដីកា JCE")។

[3] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យស្នើសុំរបស់លោកអៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្ម រួម, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ D97។

[4] ដីកា JCE, កថាខណ្ឌ ៨។

[5] នៅពេលដែលមេធាវីបានស្នើថា ក.ស.ច.ស ចេញដីកាមួយស្តីពីលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបអង្កេតបានថ្លែងថា មេធាវីការពារក្តីបានស្នើសុំកាស្រាយច្បាប់ពាក់ព័ន្ធនឹងការអនុវត្តច្បាប់នោះ និង កង្វល់នៃការជូនដំណឹងសមស្របដែលផ្តល់ជូនជនត្រូវចោទ មិនពាក់ព័ន្ធនឹងបញ្ហាដូចជា អំពើប្រល័យពូជសាសន៍ដូចដែលត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីកាបង្កើត អ.វ.ត.ក"), និង កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។ *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរនៅលើលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ, D240/3, ERN: 00421137-00421140, កថាខណ្ឌ៣។ ក.ស.ច.ស បានថ្លែងថា ខ្លួនមិនបានតម្រូវអោយបញ្ជាក់អំពីការកំណត់ប្រភេទបទល្មើសស្ថាពរឡើយ រហូតដល់មានដីកាដំណោះស្រាយ។ ហើយថាដូច្នេះនៅក្នុងដំណាក់កាលនេះមិនចាំបាច់ធ្វើការវិភាគបញ្ហានេះឱ្យពេញលេញនោះទេ។ *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៤។

ថា វាមិនចាំបាច់ក្នុងការកំណត់អង្គច្បាប់ស្ដាពរហូតដល់ដីកាដំណោះស្រាយចេញសិន[6]។ បញ្ហាដែលថាតើ ក.ស.ច.ស អាចអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវតែសម្រេចនៅក្នុងដំណាក់កាលនេះនៅក្នុងដំណើរការនីតិវិធីនេះឬក៏អត់។ លោក អៀង សារី ត្រូវតែបានដឹងអំពីទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តប្រឆាំងរូបគាត់។ សហមេធាវីការពារក្ដីមានកាតព្វកិច្ចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទាំងឡាយដែលបញ្ជាក់អះអាងយុត្តាធិការរបស់ អ.វ.ត.ក។ សិទ្ធិប្ដឹងឧទ្ធរណ៍នេះនឹងលែងមានន័យ ប្រសិនបើសហមេធាវីការពារក្ដីជាដំបូងមិនត្រូវបានអនុញ្ញាតិឱ្យលើកឡើងអំពីបញ្ហានៃ យុត្តាធិការចំពោះ ក.ស.ច.ស ទេនោះ។

## II. ច្បាប់ដែលយកមកអនុវត្ត

៣. មាត្រា ២៩នៃច្បាប់បង្កើត អ.វ.ត.ក មួយផ្នែកចែងថា៖

> ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនេះ។

## III. ទឡ្ហីករណ៍

### ក. ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចមិនត្រូវបានយកមកអនុវត្តចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា៣ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ទេ

៤. មាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា៖ "ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋ

---

[6] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ៥។

កម្មនោះបានទេ...។"[7] ទោះបីយ៉ាងណា មាត្រា៣ថ្មី[8] អនុវត្តបានចំពោះបទឧក្រិដ្ឋក្នុងច្បាប់ជាតិរបស់កម្ពុជា ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ ដោយសារថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមាននៅក្នុងច្បាប់ជាតិរបស់កម្ពុជា វាមិនអាចមកអនុវត្តចំពោះបទឧក្រិដ្ឋក្នុងច្បាប់ជាតិកម្ពុជាបានទេ។ ក.ស.ច.ស បានទទួលស្គាល់បញ្ហានេះ នៅពេលខ្លួនដាក់កម្រិតភាពអាចយកមកអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម (JCE) ទៅក្នុងបទឧក្រិដ្ឋអន្តរជាតិ ពីព្រោះការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម មិនមាននៅក្នុងច្បាប់ជាតិរបស់កម្ពុជាទេ[9] ។ ការទទួលខុសត្រូវតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវតែបានដាក់ព្រំដែនកម្រិតស្រដៀងគ្នានេះដែរ។

**ខ. ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចត្រូវអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ**

៥. សាលាក្តីក្រោយសង្គ្រាមលោកលើកទី២ ដែលបានអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ បានធ្វើការជំនុះជម្រះតែទៅលើរឿងក្តី ដែលបានកើតឡើងក្នុងបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ ដូច្នេះតុលាការទាំងនេះអាចបង្កើតយុត្តិសាស្ត្រសម្រាប់សំណុំរឿងដែលបានកើតឡើងក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ ។ ស្រដៀងគ្នានេះដែរ មានពឹងផ្អែកលើពិធីសារបន្ថែម I ដែលគាំទ្រការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងទម្លាប់អន្តរជាតិ[10] អាចអនុវត្តបាន

---

[7] គូសបញ្ជាក់បន្ថែម។

[8] មាត្រា ៣ថ្មី ក្នុងផ្នែកដែលពាក់ព័ន្ធ៖

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖

- មនុស្សឃាត (មាត្រា៥០១.៥០៣.៥០៤.៥០៥.៥០៦.៥០៧ និងមាត្រា៥០៨)
- ទារុណកម្ម (មាត្រា៥០០)

ការវាយប្រហារលើសាសនា (មាត្រា២០៩ និងមាត្រា២១០) ...

[9] ដីកា JCE, កថាខណ្ឌ ២២-២៣។

[10] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត*, IT-96-21-T, សាលក្រម ("សាលក្រម *Čelebići*"), ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨, កថាខណ្ឌ ៣៤០។ "[អា]ចមិនមានមន្ទិលថា ទស្សនទាននៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គលរបស់ថ្នាក់លើ ចំពោះការខកខានមិនបានចាត់វិធានការណ៍នោះ បច្ចុប្បន្ននេះត្រូវបានដាក់យ៉ាងពិសេសនៅក្នុងកម្រងច្បាប់មនុស្សធម៌អន្តរជាតិ។ តាមរយៈការអនុម័តពិធីសារបន្ថែមទី I គោលការណ៍នេះបច្ចុប្បន្នត្រូវបានចងក្រង និងត្រូវបានផ្តល់ជូននូវការបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងអនុសញ្ញាអន្តរជាតិ។ ដូច្នេះ មាត្រា ៨៧ នៃពិធីសារនេះផ្តល់ការបញ្ជាក់ទៅលើកាតព្វកិច្ច

ចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ពិធីសារបន្ថែម II ដែលអាចអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិមិនបានចែងបទប្បញ្ញត្តិស្រដៀងគ្នានេះទេ។ មិនមានមូលដ្ឋានដែលបានបង្កើតឡើងសម្រាប់អនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងជម្លោះផ្ទៃក្នុងដែលបានកើតឡើងក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ទេ។ ក្នុងឆ្នាំ ១៩៩៣ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បានបញ្ជាក់នូវការជឿជាក់របស់ខ្លួនថាការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មសង្គ្រាម អនុវត្តបានតែចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ[11]។

៦. ទោះជាមានកង្វះខាតយុត្តិសាស្ត្រដែលបង្ហាញថាការទទួលខុសត្រូវរបស់ថ្នាក់លើ អាចអនុវត្តបានតែចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុងក៏ដោយ ក្នុងឆ្នាំ២០០៣ អង្គជំនុំជម្រះតុលាការកំពូល ICTY *Hadžihasanović* បានសម្រេចថាការទទួលខុសត្រូវរបស់ថ្នាក់លើ អាចយកមកអនុវត្តបានចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលបានកើតឡើងក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង[12] ។ ទោះជា អ.វ.ត.ក មិនមានកាតព្វកិច្ចទាក់ទងនឹងការកំណត់របស់អង្គជំនុំជម្រះ ICTY ក៏ដោយ វាជាការសំខាន់ដើម្បីពិចារណានូវការសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះនិងកំណត់ថាតើវាមានកំហុសដែរឬទេ។

៧. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះ បានថ្លែងថាបញ្ហានេះផ្អែកទៅលើគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលខ្លួនបានកំណត់ (ដោយពិចារណាទៅលើមាត្រា១នៃបទបញ្ញត្តិស្តីពីច្បាប់និងទម្លាប់នៃសង្គ្រាមដែនដី ដែលត្រូវបានដាក់បញ្ចូលជាឧបសម្ព័ន្ធក្នុងអនុសញ្ញាក្រុងឡាអេទី៤ ក្នុងឆ្នាំ១៩០៧ មាត្រា៨៣ (១) នៃពិធិសារបន្ថែម I មាត្រា ៣ ដែលស្របនឹងអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងសេចក្តីអធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងមាត្រា ១(១) នៃពិធិសារបន្ថែម II) មានលក្ខណៈដូចគ្នានឹងជម្លោះប្រដាប់អាវុធអន្តរជាតិ និងជម្លោះប្រដាប់អាវុធ

---

របស់ថ្នាក់លើដើម្បីត្រួតត្រាអំពើរបស់ជនក្រោមបង្គាប់របស់ខ្លួន និង ដើម្បីទប់ស្កាត់ ឬ ប្រសិនបើចាំបាច់ ដើម្បីបង្ក្រាបការរំលោភលើសន្ធិសញ្ញា ឬ ពិធីសារក្រុងហ្សឺណែវ"។

[11] *សូមមើល* Christopher Greenwood, *International Humanitarian Law and the* Tadić *Case*, 7 EUR. J. INT'L L. ទំព័រ២៦៥, ២៨០ (ឆ្នាំ១៩៩៦), *ដកស្រង់* ការកត់សម្គាល់បឋមដែលមិនទាន់បានបោះពុម្ពនៃ ICRC ស្តីពីសេចក្តីព្រៀងលក្ខន្តិកៈសម្រាប់តុលាការ ICTY, ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៣។

[12] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត*, IT-01-47-AR72, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ជំទាស់នឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ ៣១។

ផ្ទៃក្នុង[13]។ អង្គជំនុំជម្រះតុលាការកំពូល *Hadžihasanović* មិនបានពិចារណាការពិតដែលថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មានចែងក្នុងនៃពិធិសារបន្ថែម I តែមិនចែងក្នុងពិធិសារបន្ថែម II ទេ ដើម្បីឱ្យមានឥទ្ធិពលទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួន។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Hadžihasanović* បានថ្លែងថា "ការមិនយោងនូវពិធិសារបន្ថែម II ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធផ្ទៃក្នុង មិនមានឥទ្ធិពលសំខាន់ទៅលើបញ្ហាដែលថា តើការទទួលខុសត្រូវរបស់ថ្នាក់លើ បានកើតមានរួចទៅហើយថាជាផ្នែកនៃទម្លាប់អន្តរជាតិទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធផ្ទៃដែរឬក៏អត់។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា វាមានការពាក់ព័ន្ធក្នុងអំឡុងពេលពាក់ពន្ធ័ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ហើយថាការសន្និដ្ឋាននេះ មិនត្រូវបានច្រានចោលដោយការប្រើប្រាស់នូវកត្តាផ្សេងៗបណ្តាលឱ្យមានភាពស្ងៀមស្ងាត់ដោយសារហេតុផលមួយចំនួន ដែលជួនកាលកើតមានក្នុងអំឡុងពេលពេលតាក់តែងឱ្យទៅជាច្បាប់នូវចំណុច ដែលត្រូវទទួលយកក្នុងការធ្វើសេចក្តីព្រាងនៃលិខិតូបករណ៍អន្តរជាតិមួយ[14]។

៨. យោងតាមសាស្ត្រាចារ្យ van Schaack សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល មានភាពខ្វះចន្លោះ ។ លោកស្រីពន្យល់ថា ៖

> ក្នុងការវិភាគនេះ ICTY មើលរំលងយ៉ាងខ្លាំងទៅលើហេតុផលជាក់ស្តែងដែលរដ្ឋនានាអាចជ្រើសរើសមិនអនុវត្តទ្រឹស្តីទាក់ទងនឹងជម្លោះប្រដាប់អាវុធ ដែលមិនមានលក្ខណៈអន្តរជាតិ នៅពេលរដ្ឋនានាធ្វើសេចក្តីព្រាងពិធីសារ II ។ បន្ថែមលើការពិតដែលថាតាមប្រវត្តិសាស្ត្រ រដ្ឋនានាមានការស្ទាក់ស្ទើរក្នុងការបង្កើតវិធានចងជាប់ជាកាតព្វកិច្ចដើម្បីដោះស្រាយជម្លោះផ្ទៃក្នុង ប្រហែលជា ពួកគេបានពិចារណាទ្រឹស្តីដែលមិនអាចអនុវត្តបានក្នុងជម្លោះបែបនេះ នៅពេលដែលកម្លាំងប្រដាប់អាវុធដែលអាចមិនមានការរៀបចំត្រឹមត្រូវ និងបានកើតឡើងដោយឯកឯង ហើយខ្សែចង្វាក់នៃសិទ្ធិអំណាចដែលយកមកអនុវត្តអាចត្រូវបានប្រកាសដោយខ្លួនឯងដោយតាមការជាក់ស្តែង de facto និងមានលក្ខណៈវិមជ្ឈការ ។ ពិតហើយ គោលការណ៍ឯកភាពនៃការបញ្ជា ដែលបានចែងថា មានតែមេបញ្ជាការតែមួយគត់ ក្នុងឋានានុក្រមយោធាកម្រិតណាក៏ដោយដែលមានសិទ្ធិ

---

[13] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១៤-១៥។

[14] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ២៩។

បញ្ហាអ្នកនៅក្រោមបង្គាប់ អាចត្រូវបានកាត់បន្ថយ ឬមិនមានវត្តមានទាំងស្រុងក្នុងបរិបទជម្លោះប្រដាប់អាវុធមិនមានលក្ខណៈអន្តរជាតិ [15]។

៩. លោក Sir Christopher Greenwood ដែលបច្ចុប្បន្នជាសមាជិកតុលាការយុត្តធម៌អន្តរជាតិ រិះគន់ចំពោះការសម្អាងរបស់អង្គជំនុំជម្រះតុលាការកំពូលនេះថា ៖

> ទោះជាអ្វីដែលអង្គជំនុំជម្រះបានលើកឡើង អំពីការបំពេញតម្រូវការដែលថាការអនុវត្តរបស់រដ្ឋ បានទទួលស្គាល់គោលការណ៍នេះក៏ដោយ សេចក្តីសម្រេចនេះ ស្ទើរតែមិនបានលើកឡើងពីការអនុវត្តរបស់រដ្ឋ និងយល់ស្របថា "នៅផ្ទៃក្នុងប្រទេស រដ្ឋភាគច្រើនមិនបានតាក់តែងច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីធ្វើជាសមភាគីទទួលខុសត្រូវក្នុងជម្លោះផ្ទៃក្នុងទេ"។ វាមិនពន្យល់ហេតុអ្វីបានជាទស្សនៈទាននៃការបញ្ហាដែលមានទទួលខុសត្រូវ ដែលតម្រូវឲ្យយុទ្ធការីទទួលខុសត្រូវចំពោះភារកិច្ច ជាស្វ័យប្រវត្តិមិនអាចជៀសផុតពីការជាប់ពាក់ព័ន្ធ ក្នុងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់បុគ្គលម្នាក់ៗឡើយ ។ វាក៏មិនបានពន្យល់ពីមូលហេតុនៃភាពមិនសមហេតុផលចំពោះទស្សនៈទាននៃទម្លាប់មនុស្សធម៌អន្តរជាតិ ដែលអាចអនុវត្តចំពោះជម្លោះអន្តរជាតិ ប៉ុន្តែមិនអនុវត្តបានចំពោះជម្លោះផ្ទៃក្នុងទេ ។ ទោះជាយ៉ាងណាក៏ដោយ មានការយល់ស្របថាគោលការណ៍ទាំងអស់នៃច្បាប់ មិនមានវិសាលភាពគ្របដណ្តប់ជម្លោះទាំងពីរប្រភេទនេះទេ។ ពិតហើយ បុគ្គលម្នាក់អាចជំទាស់ថាការទទួលខុសត្រូវរបស់ថ្នាក់លើដោយវិធីខុសគ្នាមួយអាចមានភាពសមស្រប ចំពោះជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈអន្តរជាតិពីព្រោះកម្លាំងប្រដាប់អាវុធ ដែលមានការពាក់ពន្ធ័ក្នុងជម្លោះបែបនេះមានរចនាសម្ពន្ធ័និងមានការរៀបចំតូចជាង (ជាពិសេសផ្នែកក្រៅរដ្ឋាភិបាល) ក្នុងអរិភាពអន្តជាតិ។ វាក៏ជាការសំខាន់ដែលចងចាំថាកាលពី ១០ឆ្នាំមុនតែប៉ុណ្ណោះ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បង្ហាញទស្សនៈថាច្បាប់អន្តរជាតិ មិនបានដាក់ឲ្យមានការទទួលខុសត្រូវទាល់តែសោះ ចំពោះការរំលោភច្បាប់ក្នុងជម្លោះប្រដាប់អាវុធ [16]។

---

[15] Beth van Schaack, *Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals*, 97 GEO. L.J. 119, 145 (2008)។

[16] Christopher Greenwood, CMG, QC, *Notes and Comments: Command Responsibility and the Hadžihasanović Decision*, 2.2 J. INT'L CRIM. JUST. ទំព័រ ៥៩៨, ៦០១ (២០០៤)។ Major Michael L. Smidt ពន្យល់ថា

១០. ទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើងតាមការអនុវត្តរបស់រដ្ឋ និង*ជំនឿដែលជឿថាវាជាច្បាប់* (*opinion juris*) [17]។ អង្គជំនុំជម្រះតុលាការកំពូល *Hadžihasanović* បានទទួលស្គាល់ថា "វាជាការពិតដែលថានៅក្នុងផ្ទៃប្រទេស រដ្ឋភាគច្រើនមិនបានបង្កើតច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើដើម្បីបង្កើតឱ្យមានសមភាគីទទួលខុសត្រូវ ចំពោះការបញ្ជាក្នុងជម្លោះផ្ទៃក្នុងទេ[18]"។ កង្វះនៃការអនុវត្តរបស់រដ្ឋនិង*ជំនឿដែលជឿថាវាជាច្បាប់* (*opinion juris*) ដើម្បីបង្កើតការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង មិនអាចព្រងើយកន្តើយបានឡើយ ។ ប្រសិនបើអ.វ.ត.ក អាចអនុវត្តទម្លាប់អន្តរជាតិ និងប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានពិចារណាថាជាទម្លាប់អន្តរជាតិក្នុងអំឡុងពេលនេះ វាគ្រាន់តែត្រូវបានពិចារណាថាជាទម្លាប់អន្តរជាតិទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ ។

## គ. ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចអនុវត្តបានចំពោះមេបញ្ជាការយោធាតែប៉ុណ្ណោះ

១១. ទោះជាការទទួលខុសត្រូវរបស់ថ្នាក់លើ ពេលខ្លះត្រូវបានអនុវត្តចំពោះថ្នាក់លើដែលមិនមែនជាយោធាដោយសាលាក្តីក្រោយសង្គ្រាមលោកទី២ ក៏ដោយ[19] ក៏មិនមានការអនុវត្តជាទូទៅនិងជាប់

---

"ខណៈដែលពិធីសារទី I ចងក្រងការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងជំលោះប្រដាប់អាវុធអន្តរជាតិ ពិធីសារទី II ដែលទាក់ទងនឹងជំលោះប្រដាប់អាវុធមិនអន្តរជាតិ មិនមាននិយាយអ្វីសោះអំពីបញ្ហានេះ។ អ្នកធ្វើសេចក្តីព្រៀងអាចបានទទួលស្គាល់ពីភាពលំបាកក្នុងការកំណត់ខ្សែរសង្វាក់នៃការបញ្ជានៅក្នុងកងកម្លាំងមានភាពមិនប្រក្រតី។ អាចមានភាពស្ទាក់ស្ទើរសូម្បីតែដើម្បីទទួលស្គាល់ទស្សនទាននៃការបញ្ជា នៅក្នុងកងកម្លាំងបះបោរ ពីព្រោះធ្វើដូច្នេះប្រហែលជាផ្តល់ឱ្យនូវភាពស្របច្បាប់មួយចំនួនដល់ពួកបះបោរ និងជាជំហានមួយឆ្ពោះទៅរកប្រភេទនៃឋានៈរបស់ក្រុមនោះ។ ចំពោះកងកម្លាំងរបស់រដ្ឋាភិបាលនៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង ការសម្រេចចិត្តនៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្ម អាចត្រូវបានទុកឱ្យរដ្ឋនោះជាអ្នកសម្រេច។ ភាពស្ទាក់ស្ទើរជាធម្មតារបស់សហគមន៍អន្តរជាតិដើម្បីភ្ជាប់ខ្លួនទៅនឹងជំលោះប្រដាប់អាវុធផ្ទៃក្នុង កើតចេញពីទស្សនទានដែលថាច្បាប់អន្តរជាតិហូរចេញពី 'ទស្សនទានមូលដ្ឋាននៃសមភាពឯករាជ្យ'។ ដរាបណាមានជាប់ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខសមូហភាព ឧទាហរណ៍ អង្គការសហប្រជាជាតិ ត្រូវបានហាមឃាត់មិនឱ្យអន្តរាគមន៍នៅក្នុងបញ្ហាដែលមានលក្ខណៈផ្ទៃក្នុងជាពិសេស។" Major Michael L. Smidt, *Yamashita, Medina, and Beyond: Command Responsibility in Contemporary Military Operations*, 164 MIL. L. REV. ទំព័រ១៥៥, ២០៥ (២០០០)។

[17] *សូមមើល North Sea Continental Shelf Cases,* ICJ Reports (1969) កថាខណ្ឌ ៧៤ ។

[18] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត,* IT-01-47-AR72, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ជំទាស់នឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ ១៧។

[19] *សូមមើល ឧទាហរណ៍,* សាលក្រម IMTFE។ *ការជំនុំជម្រះក្តី Friedrich Flick និងអ្នកផ្សេងទៀត,* ក្បាលទី VI, ការជំនុំជម្រះជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nürnberg ក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០, (បោះពុម្ពដោយ U.S. Govt. Printing Office: Washington 1950)។ *រឿងក្តី Government Commissioner of the General*

លាប់របស់រដ្ឋ ដើម្បីឲ្យថ្នាក់លើដែលមិនមែនជាឃោធាទទួលខុសត្រូវ ចំពោះអំពើរបស់អ្នកដែលនៅក្រោមបង្គាប់ខ្លួននៅពេលនោះ ឬក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ឡើយ។ ប្រភពដើមនៃទស្សនៈទាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានរកឃើញក្នុង "វប្បធម៌ដែលមានលក្ខណៈពិសេសនៃអង្គការចាត់តាំងយោធា និងមានភាពប្រទាក់ក្រឡាគ្នាជាមួយទស្សនាទានសំខាន់ៗក្នុងច្បាប់សង្គ្រាម"[20] ។ លោកសាស្ត្រាចារ្យ Bassiouni គូសបញ្ជាក់ថា ៖

> ក្នុងការវាយតម្លៃបទដ្ឋាន និងមាត្រដ្ឋានអន្តរជាតិដែលទទួលស្គាល់ក្នុងច្បាប់យោធាជាតិ ធៀបទៅនឹងបទដ្ឋាន និងមាត្រដ្ឋាននៃ "ការទទួលខុសត្រូវរបស់ថ្នាក់លើ"ជាស៊ីវិលក្នុងប្រពន្ធ័យុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មសំខាន់ៗក្នុងសាកលលោក វាបង្ហាញឲ្យឃើញថា បទដ្ឋាន និងមាត្រដ្ឋានអន្តរជាតិដែលទទួលស្គាល់ក្នុងច្បាប់យោធាជាតិ ត្រូវបានអនុវត្តច្រើនជាងបទដ្ឋាននិងមាត្រដ្ឋាននៃ "ការទទួលខុសត្រូវរបស់ថ្នាក់លើ"ជាស៊ីវិល។ ហេតុផលសំខាន់ក្នុងស្ថានភាពនេះ គឺកង្វះខាតនូវគោលនយោបាយច្បាប់ដែលមានភាពជាប់លាប់នៅក្នុងប្រទេសស្ទើរតែទាំងអស់ក្នុងសាកលលោក ដែលអនុញ្ញាតឲ្យមានការបែងចែកទិដ្ឋភាពផ្សេងៗគ្នានៃច្បាប់[21]។

---

*Tribunal of the Military Government for the French Zone of Occupation in Germany តទល់នឹង Herman Roechling និងអ្នកផ្សេងទៀត*, ការផ្តន្ទាទោសនិងសាលក្រមរបស់ General Tribunal of the Military Government of the French Zone of Occupation in Germany, ក្បាលទី XIV, TWC, សេចក្តីបន្ថែម ខ, ទំព័រ១០៦១ អាចស្វែងរកបាននៅគេហទំព័រ *available at* http://www.loc.gov/rr/frd/Military_Law/pdf/NT_war-criminals_Vol-XIV.pdf.

[20] Jenny S. Martinez, *Understanding* Mens Rea *in Command Responsibility: From Yamashita to Blaškić and Beyond*, 53 J. INT'L CRIM. JUST. 638 (2007) ។

[21] CHERIF BASSIOUNI, INTRODUCTION TO INTERNATIONAL CRIMINAL LAW ទំព័រ ៣១៨ (បោះពុម្ពដោយTransnational Publishers, ឆ្នាំ២០០៣)។ *សូមមើលផងដែរ* ទំព័រ ៣២០។ "ថាវីដែល[មិ]នមែនជាយោធានឹងត្រូវបានកាត់សេចក្តីស្របតាមនិយាមនិងបទដ្ឋានជាតិ នៃច្បាប់ព្រហ្មទណ្ឌស៊ីវិល និងថាតាមពិតនោះមិនកំណត់ឯកសណ្ឋានមូលដ្ឋានច្បាប់អន្តរជាតិនៃការទទួលខុសត្រូវនោះទេ។ វាស្ទើតែមិនអាចទៅរួចទេ ក្នុងការសាកល្បងបង្កើតនិយាមនិងបទដ្ឋានស៊ីវិលអន្តរជាតិស្តីពីគោលការណ៍រួមនោះ ដោយសារភាពផ្សេងគ្នានៅក្នុងនិយាមនៃការទទួលខុសត្រូវ និងលទ្ធភាពនៃការចោទប្រកាន់ នៅក្នុងប្រព័ន្ធតុលាការឧក្រិដ្ឋកម្មសំខាន់បំផុតរបស់ពិភពលោក ដូចដែលបានពិភាក្សាខាងលើ។"

១២. បន្ថែមពីនេះទៅទៀត មាត្រា៨៧ មានការយោងជាក់លាក់ចំពោះ "មេបញ្ជាការយោធា[22]" និងរដ្ឋនានាដែល " មេបញ្ជាការ ធានាថាសមាជិកនៃកងប្រដាប់អាវុធនៅក្រោមបញ្ជារបស់ខ្លួន ដឹងថាកាតព្វកិច្ចរបស់ពួកគេមានចែងនៅក្នុងអនុសញ្ញា និងពិធីសារនេះ។" [23]

**ឃ. ការទទួលខុសត្រូវរបស់ថ្នាក់លើតែនៅពេលណា ដែលមានទំនាក់ទំនងហេតុនិងផលរវាងអំពើរបស់មេដឹកនាំ និងបទល្មើសរបស់អ្នកនៅក្រោមបង្គាប់មេដឹកនាំនោះ និងនៅពេលដែលមានបទល្មើសទាក់ទងនឹងសកម្មភាពទាំងឡាយ ដែលថ្នាក់លើមានកាតព្វកិច្ចផ្លូវច្បាប់ដែលកើតមានជាមុនរួចជាស្រេចដើម្បីបង្ការនិងដាក់ទោស**

**១) ការទទួលខុសត្រូវរបស់ថ្នាក់លើ តម្រូវឱ្យហេតុនិងបច្ច័យ**

១៣. ប្រសិនបើសំណុំរឿងក្រោយសង្គ្រាមលោកលើកទី២ ជាភស្តុតាងនៃទម្លាប់អន្តរជាតិ សំណុំរឿងទាំងនោះ បង្ហាញថាទម្លាប់អន្តរជាតិតម្រូវឱ្យថ្នាក់លើម្នាក់ ទទួលខុសត្រូវចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ នៅពេលដែលបទឧក្រិដ្ឋទាំងនេះ បានកើតឡើង<u>ជាលទ្ធផល</u>នៃការខកខានមិនបានធ្វើរបស់ថ្នាក់លើ ។ ឧទាហរណ៍ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង* Wilhelm List តម្រូវឱ្យមាន "ភស្តុតាងនៃហេតុនឹងបច្ច័យ អំពើដែលបង្ហាញមូលហេតុយ៉ាងច្បាស់ ឬការខកខានមិនបានធ្វើដែលគេអាចសន្និដ្ឋានបានពីចេតនាប្រព្រឹត្តបទល្មើស។[24]" ក្នុងសាលដីកា IMTFE លោកចៅក្រម Bernard នៃប្រទេសបារាំង បានថ្លែងថា "ការទទួលខុសត្រូវចំពោះការខកខានមិនបានធ្វើ សន្មតនូវការប្រព្រឹត្តជាចុងក្រោយ ក្រោយពីការខកខានមិនបានធ្វើ និងមានប្រភពចេញពីបុគ្គលដែលត្រូវបានគេទម្លាក់ការទទួលខុសត្រូវនូវការខកខានមិនបានធ្វើ ពីបុគ្គលម្នាក់ឬបុគ្គលមួយចំនួនទៀត។ "ការទទួលខុសត្រូវចំពោះលទ្ធផលនៃការខកខានមិនបានធ្វើ ត្រូវបានគេទម្លាក់ការទទួលខុសត្រូវលើអ្នកផ្តើមគំនិតនូវការខកខានមិនបានធ្វើ ប្រសិនបើការប្រព្រឹត្តកើតចេញជាលទ្ធផលណាមួយដោយសារការខកខានមិនបានធ្វើ [25]"។ ក្នុងរឿងក្តី Schonfeld et al លោកចៅក្រមតុលាការយោធាបានថ្លែងថា បទឧក្រិដ្ឋត្រូវតែជាលទ្ធផលធម្មតានៃការធ្វេសប្រហែសរបស់ជនជាប់ចោទ

---

[22] ពិធីសារបន្ថែម I, មាត្រា ៨៧(១)។

[23] *ដូចដើងទំព័រខាងលើ,* មាត្រា ៨៧(២)។

[24] *រឿងក្តី United States តទល់នឹង Wilhelm List និងអ្នកផ្សេងទៀត,* ក្បាលទី XI, ការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ ទំព័រ ១២៦១។

[25] ដូចដែលបានដកស្រង់ក្នុង GUÉNAËL METTRAUX, THE LAW OF COMMAND RESPONSIBILITY 84 (បោះពុម្ពដោយ Oxford University Press, 2009)។

អាចនិយាយម៉្យាងទៀតថាការផ្តល់សេចក្តីណែនាំពីជនជាប់ចោទ នៅពេលត្រឹមត្រូវណាមួយអាចត្រូវបានទប់ស្កាត់មិនឲ្យការសម្លាប់ដោយមិនមានហេតុផលសមស្របកើតឡើង។ [26]

១៤. "ទោះយ៉ាងណាតុលាការ ICTY ដែលក្នុងស្ថានភាពដែលបង្ហាញឲ្យឃើញនូវកង្វះតម្រូវការនៃទម្លាប់អន្តរជាតិ[27]" បានសម្រេចថាតម្រូវការហេតុនិងបច្ច័យ មិនមានភាពចាំបាច់។ សំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង *Čelebići* បានថ្លែងថាទម្លាប់អន្តរជាតិមិនតម្រូវឲ្យមានភស្តុតាងនៃទំនាក់ទំនងជាធម្មតា រវាងការប្រព្រឹត្តរបស់ជនជាប់ចោទ និងបទឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់គាត់។[28] អង្គជំនុំជម្រះតុលាការកំពូល *Blaškić* បានគូសបញ្ជាក់ថាសំណុំរឿងរបស់អង្គជំនុំជម្រះតុលាការកំពូល *Čelebići* មិនបានទាញសម្អាងនូវសិទ្ធិអំណាចណាមួយសម្រាប់សេចក្តីអះអាងនេះទេ [29]។ ទោះជាយ៉ាងណាក៏ដោយ សាលដីកាបន្តបន្ទាប់នៅតុលាការ ICTY បានអនុម័តទស្សនៈនេះដោយមិនបានធ្វើការវិភាគដោយឯករាជ្យ ។ [30]

១៥. ទោះជាច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រៀបចំដាក់ការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងស្ថានភាពស្រដៀងគ្នាទៅនឹងមាត្រា ៧(៣) នៃលក្ខន្តិកៈតុលាការ ICTY ទាក់ទងទៅនឹងហេតុនិងបច្ច័យក៏ដោយ ក៏លក្ខន្តិកៈ ICC អាចឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវការអភិវឌ្ឍនៃទម្លាប់អន្តរជាតិ ។ មិនដូចតុលាការ ICTY មាត្រា២៨ នៃលក្ខន្តិកៈតុលាការ ICC មិនតម្រូវឲ្យហេតុនិងបច្ច័យទេ ។ មាត្រានេះចែងថា "ថ្នាក់លើម្នាក់ ត្រូវទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋ...ដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ក្រោមសិទ្ធិអំណាច និងការត្រួតត្រាដោយមានប្រសិទ្ធិភាពរបស់ខ្លួន <u>ជាលទ្ធផល</u>នៃការខកខានមិនបានត្រួតពិនិត្យដោយសមស្របទៅលើអ្នកនៅក្រោមបង្គាប់ទាំងនោះ ...។"

---

[26] *ដូចជើងទំព័រខាងលើ។*

[27] *ដូចជើងទំព័រខាងលើ*, ទំព័រ៨៣។

[28] សាលក្រម *Čelebići*" កថាខណ្ឌ ៣៩៨។

[29] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Blaškić*, IT-95-14-A, សាលដីកា, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤, កថាខណ្ឌ ៧៦។

[30] *សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Kordić & Čerkez*, IT-95-14/2-A, សាលដីកា, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤, កថាខណ្ឌ ៨៣០-៨៣២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Halilović*, IT-01-48-T, សាលក្រម, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥, កថាខណ្ឌ ៧៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Orić*, IT-03-68-T, សាលក្រម, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦, កថាខណ្ឌ ៣៣៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Brđanin*, IT-99-36-T, សាលក្រម, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤, កថាខណ្ឌ ២៨០។

២. ប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានរកឃើញថាយកមកអនុវត្ត ចំពោះថ្នាក់ដឹកនាំជាស៊ីវិលនោះ ការទទួលខុសត្រូវរបស់ថ្នាក់លើ តម្រូវឲ្យពួកគាត់ ទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋពាក់ពន្ធ័នឹងសកម្មភាពដែលត្រូវទទួល ខុសត្រូវ និងស្ថិតក្រោមការគ្រប់គ្រងដោយមានប្រសិទ្ធិភាពរបស់ខ្លួន

១៦. ជនស៊ីវិលជាមេដឹកនាំថ្នាក់លើ អាចដាក់អោយទទួលខុសត្រូវចំពោះការខកខានមិនបានបង្ការ ឬ ដាក់ទោសទណ្ឌនៅពេលពួកគេជាដំបូងមានកាតព្វកិច្ចដើម្បីបង្ការ ឬ ដាក់ទោសទណ្ឌ។ យោងទៅ តាមសាស្ត្រាចារ្យ Zahar និង Sluiter ថ្វីបើលក្ខខណ្ឌតម្រូវនៃកាតព្វកិច្ចគឺមិនមានរាយនាមថាជា ធាតុផ្សំដោយឡែកនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់លក្ខន្តិកៈរបស់តុលាការ *ចំពោះ កិច្ច ad hoc* នានា "វានៅមានចែងបង្កប់នៅក្នុងបទប្បញ្ញត្តិនោះ" [31]។ នេះគឺដោយសារ "គោលការណ៍ច្បាប់ទូទៅ គឺចែងអំពីការខកខាននឹងបណ្តាលអោយមានការទទួលខុសត្រូវ ដរាប បើសិនជាវាអាចទៅរួច ដើម្បីបង្កើតអោយមានកាតព្វកិច្ចត្រូវចាត់វិធានការ" [32]។

១៧. ខុសពីច្បាប់លក្ខន្តិកៈនៃតុលាការ *ចំពោះកិច្ច ad hoc* នានា វិធាន២៨ នៃលក្ខន្តិកៈតុលាការ ICC ចែងថា "ថ្នាក់លើម្នាក់ ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ...ដែល (ii) បទឧក្រិដ្ឋទាក់ទងនឹង <u>សកម្មភាព ដែលស្ថិតនៅក្នុងការទទួលខុសត្រូវ និងការគ្រប់គ្រងដោយមានប្រសិទ្ធិភាពរបស់ថ្នាក់ លើ</u>...។" ភាសាដែលបានលើកឡើងនេះ បង្កើតឲ្យភាពមានទំនាក់ទំនងគ្នារវាងបទឧក្រិដ្ឋ និង សកម្មភាពស្ថិតក្នុងការទទួលខុសត្រូវ និងការគ្រប់គ្រងរបស់ថ្នាក់លើស៊ីវិលរបស់ខ្លួន ។

១៨. តម្រូវការនៃភាពមានទំនាក់ទំនងគ្នារវាងបទឧក្រិដ្ឋ និងសិទ្ធិអំណាចរបស់ថ្នាក់លើជាស៊ីវិល មាន លក្ខណៈសមស្របនឹងសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះ *Čelebići* ថា "ខណៈដែលការទទួល ខុសត្រូវថ្នាក់លើចំពោះអំពើវិជ្ជមាន ចេញពីគោលការណ៍ទូទៅនៃការទទួលខុសត្រូវរបស់អ្នកសម គំនិត ... ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ថ្នាក់លើដែលខកខានមិនបានចាត់វិធានការទប់ ស្កាត់ឬបង្ក្រាបការប្រព្រឹត្តអំពើខុសច្បាប់របស់អ្នកនៅក្រោមបង្គាប់ ត្រូវបានយល់យ៉ាងច្បាស់ថា នៅពេលដែលគេឃើញថា មានការប្រឆាំងនឹងគោលការណ៍ដែលការទទួលខុសត្រូវចំពោះបទ

---

[31] ALEXANDER ZAHAR & GÖRAN SLUITER, INTERNATIONAL CRIMINAL LAW 259 (Oxford University Press 2008).

[32] ដូចយោងខាងលើ ទំព័រ ២៥៩ ។

ឧក្រិដ្ឋចំពោះការខកខានមិនបានធ្វើ បានកើតឡើងតែនៅពេលដែលកាតព្វកិច្ចច្បាប់តម្រូវឱ្យអនុវត្តតែប៉ុណ្ណោះ។"[33]

១៩. តម្រូវការនេះ ជួយការពារប្រឆាំងនឹងស្ថានភាពដែលថ្នាក់លើជាស៊ីវិល ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ថ្វីបើបទឧក្រិដ្ឋនេះ មិនមានអ្វីទាក់ទងទៅនឹងចរិតនៃទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ក៏ដោយ ។ ស្ថានភាពនេះ បានកើតឡើងក្នុងសំណុំរឿង *Musema* នៅតុលាការ ICTR ។ ក្នុងសំណុំរឿង *Musema* អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា *Musema* ដែលអ្នកចាត់ចែងការងាររោងចក្រតែ មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ពីព្រោះកម្មកររោងចក្រតែ បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងគាត់ខកខានមិនបានទប់ស្កាត់អំពើនេះ ឬដាក់ទណ្ឌកម្មដល់កម្មកររបស់គាត់។[34] កំហុសនៅក្នុងការសម្អាងហេតុរបស់តុលាការ ICTR គឺថា *Musema* ដែលជាអ្នកចាត់ចែងរោងចក្រតែ ទំនងមានសមត្ថភាពដាក់ទណ្ឌកម្មដល់និយោជិករបស់ខ្លួន ចំពោះការខកខានមិនបានបំពេញភារកិច្ចនៅកន្លែងធ្វើការងាររបស់ខ្លួន ប៉ុន្តែមិនមានន័យថាគាត់មានការទទួលខុសត្រូវ ឬសិទ្ធិអំណាច ដើម្បីដាក់ទោសពួកគេចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាក់ស្តែង ដែលមិនមានទំនាក់ទំនងអ្វីទៅនឹងការងាររបស់ពួកគេទេ។ សាស្ត្រាចារ្យ Zahar ពន្យល់ថាការសម្អាងរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស។

> វាមិនប្លែក *Musema* ឱ្យដាច់ចេញពីនាយករោងចក្រធម្មតាម្នាក់ទេ ។ ទោះជាយ៉ាងណាវាមិនអាចថាអ្នកចាត់ចែងមុខជំនួញទាំងអស់ ទទួលខុសត្រូវជាប់ពិរុទ្ធភាពពីបទឧក្រិដ្ឋអន្តរជាតិដែលបានប្រព្រឹត្តដោយនិយោជិករបស់ខ្លួន ដោយសារពួកគេ មានទំនាក់ទំនងការងារធម្មតាជាមួយនិយោជិករបស់ខ្លួន។ ក្នុងទម្រង់(សឹក)បុរាណ មេបញ្ជាការដែលត្រូវបានគេប្រមើលមើល [ក្នុងបទប្បញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនៃលក្ខន្តិកៈ ICTR ] ថាមានទំនាក់ទំនងជាមួយទាហានរបស់ខ្លួន មិនមែនគ្រាន់តែតាមរយៈ

---

[33] សាលក្រម *Čelebići*, កថាខណ្ឌ ៣៣៤ (គូសបញ្ជាក់បន្ថែម)។

[34] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema*, ICTR-96-13-T, សាលក្រម និង ការផ្តន្ទាទោស, ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០, កថាខណ្ឌ ៨៩៤-៨៩៥។

ទំនាក់ទំនងនៃការគ្រប់គ្រងនិយោគជិកតែប៉ុណ្ណោះទេ ប៉ុន្តែគាត់ស្ថិតនៅចំណុចកណ្តាលនៃអង្គភាពប្រយុទ្ធដែលមានអំណាចសម្រេចការស្លាប់រស់...។[35]

ង. **ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចមិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋមានចេតនាពិសេស ដូចជាអំពើប្រល័យពូជសាសន៍ជាដើម**

២០. ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមានភាពស៊ីសង្វាក់ជាមួយនឹងបទឧក្រិដ្ឋមានចេតនាពិសេសទេ[36]។ នេះគឺដោយសារមេបញ្ជាការ អាចដាក់អោយទទួលខុសត្រូវស្ថិតក្រោមការទម្រង់ទទួលខុសត្រូវរបស់ថ្នាក់លើ នៅពេលដែលខ្លួនមិនមានបំណងឲ្យបទល្មើសកើតឡើង និងអាចមិនបានដឹងពីការកើតមានឡើងនៃបទល្មើសនេះ រហូតទាល់តែវាបានកើតមានរួចទៅហើយ ។ ទោះជាយ៉ាងណាបទល្មើសមានចេតនាពិសេស ដូចជាអំពើប្រល័យពូជសាសន៍ តម្រូវឲ្យការទទួលខុសត្រូវផ្សាភ្ជាប់ទៅនឹងបទល្មើសមួយ នៅពេលដែលបទល្មើសត្រូវបានគេប្រព្រឹត្តឡើងដែលតម្រូវអោយមានចេតនាពិសេស។

> ការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះអំពើប្រល័យពូជសាសន៍ មិនមានភាពស៊ីសង្វាក់ក្នុងទិដ្ឋភាពមួយចំនួន ដោយយល់ថាបទឧក្រិដ្ឋប្រល័យពូជសាសន៍ជាបទល្មើសចង្អៀតដែលមានចេតនាពិសេស។ បញ្ហាច្រើនបង្ហាញនូវភាពត្រឹមត្រូវចំពោះការតិទៀននេះ ពីព្រោះភាពមិនស៊ីសង្វាក់គ្នាខាងទ្រឹស្តី មានវិសាលភាពចំពោះ (i)តម្រូវការនៃកំហុសដែលធានាអោយមានការផ្តន្ទាទោស (ii) វិសាលភាពនៃការកើតមានជាមុននូវភារកិច្ចរបស់ជនល្មើស (iii) សញ្ញាណដែលមានជាប់ជាមួយការទទួលខុសត្រូវជាបុគ្គល និងអវិភាពទូទៅក្នុងច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការទទួលខុសត្រូវជំនួស និង (iv) ការដាក់បញ្ចូលក្នុងជំពូកសមស្របនៃការប្រព្រឹត្តបទល្មើសដែលកំពុងមានបញ្ហា។[37]

---

[35] Alexander Zahar, *Command Responsibility of Civilian Superiors for Genocide*, 14 Leiden J. Int'l L. ទំព័រ ៥៩១, ៦0៣ (២00១)

[36] គឺជាការទទួលខុសត្រូវ តាមរយៈ JCE III សម្រាប់ហេតុផលដូចគ្នា។

[37] David L. Nersessian, *Whoops, I Committed Genocide! The Anomaly of Constructive Liability for Serious International Crimes*, 30 FLETCHER F. WORLD AFF. ទំព័រ៨១, ៩២-៩៣ (២00៦)។ Nersessian បន្តពន្យល់ទៀតថា "អំពើប្រល័យពូជសាសន៍តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានបង្កើតឡើងពីអំពើខុសគ្នាទាំងស្រុង (ការមិនទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មអំពើប្រល័យពូជសាសន៍ដោយអ្នកដទៃ) និងបន្ទាបកំហុសផ្ទាល់ខ្លួនយ៉ាងធំធេង (ការធ្វេសប្រហែសឧក្រិដ្ឋកម្ម)។ អំពើប្រល័យពូជសាសន៍អាចត្រូវបានភ្ជាប់ទៅដោយផ្ទេរបន្ទុកទៅមេបញ្ជាការ ពីព្រោះថ្នាក់លើទទួលព័ត៌មានខុស

២១. តុលាការ ICTY និង ICTR បានសម្រេចឱ្យមេបញ្ជាការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ទោះជាពួកគេមិនមានចេតនាពិសេសក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក៏ដោយ។ ទោះជាយ៉ាងណា ដូចលោកសាស្ត្រាចារ្យ Schabas កត់សម្គាល់ សេចក្តីសម្រេចទាំងនេះ "បង្ហាញពីដំណើរមិនសមស្របរបស់តុលាការចំពោះទស្សនទានរួម"។[38] ឧទាហរណ៍ លោកសាស្ត្រាចារ្យ Schabas ពន្យល់ថា "ក្នុងសំណុំរឿងអំពើប្រល័យពូជសាសន៍ ត្រូវបានគេទទួលស្គាល់ជាទូទៅថា ធាតុផ្សំអត្តនោម័តនៃបទល្មើស គឺជាធាតុផ្សំមួយនៃចេតនាពិសេស ។ ជាការសមហេតុផល វាមិនអាចទៅរួចក្នុងការផ្តន្ទាទោសបុគ្គលម្នាក់ ដែលគ្រាន់តែមានការធ្វេសប្រហែសមិនបានដឹងបទឧក្រិដ្ឋដែលមានចេតនាពិសេសមួយនោះឡើយ។[39]

## IV. សេចក្តីសន្និដ្ឋាន និងសំណើសុំការបន្ធូរបន្ថយ

២២. បើសិនជា អវតក សម្រេចថា ខ្លួនអាចយកមកអនុវត្តនូវការទទួលខុសត្រូវរបស់ថ្នាក់លើនោះ ទោះបីជាមានទឡ្ហីករណ៍ផ្ទុយពីនេះក្តី ១) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្ត ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ២) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកអនុវត្តបានតែចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ ៣) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានចំពោះតែមេដឹកនាំយោធាប៉ុណ្ណោះ ៤) ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកអនុវត្តបានតែនៅពេលណា ដែលមានទំនាក់ទំនងហេតុនិងផលរវាងអំពើរបស់មេដឹកនាំ និងបទល្មើសរបស់អ្នកនៅក្រោមបង្គាប់មេដឹកនាំនោះ និងនៅពេលដែលមានបទល្មើសទាក់ទងនឹងសកម្មភាពទាំងឡាយ ដែលថ្នាក់លើមានកាតព្វកិច្ចផ្លូវច្បាប់ដែលកើតមានជាមុនរួចជា

---

ត្រូវបានណែនាំខុស ឬ មិនបានដឹង។ បញ្ហានេះធ្វើឱ្យមានន័យតិចតួចណាស់។ ទោះបីជាការធ្វេសប្រហែសធ្ងន់ធ្ងរ គឺគួរឱ្យផ្តន្ទាទោស និងពិតជាសមនឹងទទួលទណ្ឌកម្មព្រហ្មទណ្ឌ មានភាពខុសគ្នាជាក់ស្តែងរវាងការប្រព្រឹត្តដោយចេតនា និង ការធ្វេសប្រហែសទទួលខុសត្រូវ។ ប៉ុន្តែការទទួលខុសត្រូវរបស់ថ្នាក់លើ ធ្វើឱ្យចារីផ្ទាល់ និង ថ្នាក់លើធ្វេសប្រហែស មិនសប្បាយចិត្តស្មើគ្នា និងអនុញ្ញាតឱ្យពួកគាត់ត្រូវបានផ្តន្ទាទោសដោយឧក្រិដ្ឋកម្មតែមួយដូចគ្នា។ ការបង្កើតឱ្យមានការទទួលខុសត្រូវក្នុងលក្ខណៈនេះ គឺមិនស្របទៅនឹងអំពើប្រល័យពូជសាសន៍ ជាបទល្មើសតូចដែលសំអាងលើចេតនាពិសេសដើម្បីកម្ទេចក្រុមមួយដែលទទួលបានការការពារនោះទេ។" *ដូចដឹងទំព័រខាងលើ*, ទំព័រ ៩៤។

[38] WILLIAM A. SCHABAS, GENOCIDE IN INTERNATIONAL LAW: THE CRIME OF CRIMES ទំព័រ៣០៩ (បោះពុម្ពដោយ Cambridge University Press, ឆ្នាំ ២000)។

[39] William A. Schabas, *Canadian Implementing Legislation for the Rome Statute*, 3 Y.B. INT'L HUMANITARIAN L. ទំព័រ ៣៣៧, ៣៤២ (២000) ។

ស្រេចដើម្បីបង្ការនិងដាក់ទោស និង ៥) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្ត ចំពោះបទល្មើសដែលមានចេតនាពិសេស ដូចជា អំពើប្រល័យពូជសាសន៍ជាដើមឡើយ។

**ហេតុដូច្នេះហើយ** ដូចហេតុផលទាំងអស់ដែលមានថ្លែងខាងលើ ក្រុមមេធាវីការពារក្ដី ស្នើដោយគោរពថា ថ្វីបើមានទឡ្ហីករណ៍ទាំងអស់របស់មេធាវីដែលផ្ទុយពីនេះក្ដី បើសហចៅក្រមស៊ើបអង្កេត យល់ឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចយកមកអនុវត្តបាននៅ អវតក ក្ដី កសចស គួរ៖

ក. **បដិសេធ** ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់បង្កើត អវតក

ខ. **អនុវត្ត** ការទទួលខុសត្រូវរបស់ថ្នាក់លើតែទៅលើស្ថានភាពដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិបានហើយ។

គ. **អនុវត្ត** ការទទួលខុសត្រូវរបស់ថ្នាក់លើតែនៅពេលណា ដែលមានទំនាក់ទំនងហេតុនិងផលរវាងអំពើរបស់មេដឹកនាំ និងបទល្មើសរបស់អ្នកនៅក្រោមបង្គាប់មេដឹកនាំនោះ និងនៅពេលដែលមានបទល្មើសទាក់ទងនឹងសកម្មភាពទាំងឡាយ ដែលថ្នាក់លើមានកាតព្វកិច្ចផ្លូវច្បាប់ដែលកើតមានជាមុនរួចជាស្រេចដើម្បីបង្ការនិងដាក់ទោស និង

ឃ. **បដិសេធ** ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះបទល្មើសដែលមានចេតនាពិសេស ដូចជា អំពើប្រល័យពូជសាសន៍ជាដើមឡើយ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្ដីគោរព។

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

ចុះហត្ថលេខា ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៥** ខែកុម្ភៈ ឆ្នាំ **២០១០**